**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សារលិខិតរំលែកទុក្ខ

## ជូនចំពោះ
## ក្រុមគ្រួសាររបស់លោក ពៅ នេពីន និងលោក អឿន ចាន់ដារ៉ា

*លោក និងលោកស្រី ក្រុមគ្រួសារនៃសព ជាទីគោរពរាប់អាន!*

នាងខ្ញុំ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសេចក្តីរន្ធត់ចិត្តក្តុកក្តួលយ៉ាងក្រៃលែងចំពោះមរណភាពរបស់ លោក **ពៅ នេពីន** និងលោក **អឿន ចាន់ដារ៉ា** ជាបុគ្គលិកបោសសម្អាតមីនរបស់មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) ដែលបានទទួលមរណភាព នៅថ្ងៃព្រហស្បតិ៍ ៣រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៥ វេលាម៉ោង ៧:៤៥ នាទីព្រឹក ក្នុងឧបទ្ទវហេតុផ្ទុះមីន អំឡុងពេលកំពុងប្រតិបត្តិការបោសសម្អាតមីន នៅភូមិត្រពាំងប្រិយ៍ ឃុំបាក់អន្លូង ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

ក្នុងឱកាសប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំនេះ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវសេចក្តីសោកស្តាយជាទីបំផុតចំពោះ ក្រុមគ្រួសាររបស់លោក **ពៅ នេពីន** និងលោក **អឿន ចាន់ដារ៉ា** ដែលនេះជាការបាត់បង់វីរជនដោះមីនដ៏អង់អាចក្លាហាន ដែលតែងតែលះបង់កម្លាំងកាយចិត្ត និងពេលវេលា ដើម្បីសុខសុវត្ថិភាពរបស់ប្រជាជនរស់នៅតំបន់ប្រឈមនឹងគ្រាប់មីន ព្រមទាំងបានចូលរួមធ្វើពលិកម្មគ្រប់បែបយ៉ាងប្រកបដោយឆន្ទៈមនសិការដ៏មោះមុត ក្នុងបុព្វហេតុបម្រើជាតិ សាសនា ព្រះមហាក្សត្រ និងការពារបូរណភាពទឹកដីជារៀងរហូតមក។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នា សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធរបស់ លោក **ពៅ នេពីន** និងលោក **អឿន ចាន់ដារ៉ា** សូមបានទៅសោយសុខក្នុងឋានសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម ក្រុមគ្រួសាររបស់លោក **ពៅ នេពីន** និងលោក **អឿន ចាន់ដារ៉ា** ទទួលនូវការចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំនេះ និងការស្រលាញ់រាប់អានយ៉ាងជ្រាលជ្រៅពីយើងខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៥

**រដ្ឋមន្ត្រីស្តីទី**

**សុខណ្ណ វណ្ណារតន៍**

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*